**ការចេញផ្សាយបន្ទាន់**

## កូកា-កូឡា ឧបត្ថម្ភពិធីបុណ្យអុំទូកនៅភ្នំពេញ ឆ្នាំ ២០០០
## ការឧបត្ថម្ភដល់ទូក និង គណៈកម្មាធិការបុណ្យ
## ព្រមទាំងការផ្តល់ជូនភេសជ្ជៈមួយចំណែកដល់ទូចការគ្រោះ ពិធីបុណ្យប្រចាំឆ្នាំរបស់កម្ពុជា
## ភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០០០

ថ្ងៃនេះក្រុមហ៊ុនកូកា-កូឡា បានចេញសេចក្តីប្រកាសពីការឧបត្ថម្ភពិធីបុណ្យអុំទូកក្នុងឆ្នាំនេះ ជាមួយរាល់សកម្មភាពទាំងអស់ដែលបង្ហាញពីការសប្បាយរីករាយនៃព្រឹត្តិការណ៍ជាទំនៀមទំលាប់ប្រពៃណីរបស់ប្រជាជនកម្ពុជា។

កូកា-កូឡា គឺជាក្រុមហ៊ុនផលិតភេសជ្ជៈមួយដ៏ល្បីនៅលើពិភពលោក ដែលមានរោងចក្រនៅក្នុងទីក្រុងភ្នំពេញ នឹងចូលរួមឧបត្ថម្ភទូកចំនួន ៥០ ក្នុងចំណោមទូកចូលរួមប្រមាណ ៤០០ និងបានផ្តល់ភេសជ្ជៈសំរាប់គណៈកម្មាធិការរៀបចំពិធីបុណ្យអុំទូក និង អ្នកចូលរួមប្រមាណ ២៥.០០០ នាក់។

ដូចប្រសាសន៍របស់អ្នកស្រី ជីធីស្ស ឡូវីន នាយកក្រុមហ៊ុនភេសជ្ជៈកម្ពុជា ដែលជាក្រុមហ៊ុនផលិតភេសជ្ជៈកូកា-កូឡា នៅទីក្រុងភ្នំពេញ បានលើកឡើងថា " ដោយបានចូលរួមនៅក្នុងព្រឹត្តិការណ៍ធំៗ នៅក្នុងសហគមន៍ ដូចជាពិធីបុណ្យអុំទូកនេះជាដើម ទាំងនៅក្នុងប្រទេសកម្ពុជា និង នៅក្នុងព្រឹត្តិការធំៗផ្សេងៗទៀតនៅជុំវិញពិភពលោក បានធ្វើឱ្យយើងកាន់តែបានភាពស្និទ្ធស្នាលជាមួយនឹងអ្នកប្រើប្រាស់ និងធ្វើឱ្យផលិតផលរបស់យើង ទៅជាផ្នែកមួយដ៏សំខាន់នៅក្នុងឱកាសមួយ ដែលមិនអាចបំភ្លេចបាន " អ្នកស្រីបានបន្ថែមទៀតថា " ក្រុមហ៊ុនកូកា-កូឡា គឺមិនត្រឹមតែជា ក្រុមហ៊ុនមួយដែលផលិត និងចែកចាយនូវភេសជ្ជៈមួយដ៏ល្បីនៅលើពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ជាសមាជិកនៃសហគមន៍ដ៏សំខាន់មួយដែលជានិច្ចជាកាលតែងតែចូលរួមយ៉ាងសកម្មរាល់សកម្មភាពរបស់ប្រជាជន "។

គឺជាព្រឹត្តិការណ៍ថ្មីមួយនៃសហគមន៍កម្ពុជា ដែលសកម្មភាពនៃពិធីបុណ្យអុំទូកឆ្នាំនេះ ត្រូវបានឧបត្ថម្ភដោយក្រុមហ៊ុនកូកា-កូឡា បន្ទាប់ពីបានផ្តល់នូវជំនួយជាបន្ទាន់នាពេលថ្មីៗនេះ ចំនួន ៥០០ កញ្ចប់ សំរាប់ ៥០០ គ្រួសារ ដល់ជនរងគ្រោះដោយទឹកជំនន់។ ក្រុមហ៊ុន កូកា-កូឡា នៅបានចូលរួមនៅក្នុង

ទិវាសំអាតទីក្រុងភ្នំពេញនាដើមឆ្នាំនេះ ហើយបានចូលរួមចំណែកនៅក្នុងទិវាសប្បុរសធម៌របស់កាកបាទក្រហមកម្ពុជាប្រចាំឆ្នាំ ដែលនៅពេលនោះ ថវិការដែលប្រមូលបានពីការលក់កូកា-កូឡា ទាំងអស់ត្រូវបានចូលរួម ជាវិភាគទានជូនទៅកាកបាទក្រហមកម្ពុជា។

ជាមួយនឹងការចូលរួមដ៏សំខាន់នៅក្នុងពិធីបុណ្យអុំទូក ក្រុមហ៊ុនកូកា-កូឡា បានក្លាយទៅជាចំណែកមួយដ៏សំខាន់នៃជីវភាពរស់នៅរបស់សហគមន៍ខ្មែរ និងបានផ្តល់បន្ថែមនូវកំរិតនៃការសប្បាយរីករាយក្នុងឱកាសប្រារព្ធពិធីបុណ្យដ៏ធំរបស់ប្រជាជនកម្ពុជា។

" យើងខ្ញុំមានកិត្តិយសដ៏ឧត្តុង្គឧត្តមដែលបានឧបត្ថម្ភនូវក្នុងព្រឹត្តិការណ៍ដ៏អស្ចារ្យ និង មានមោទនភាពយ៉ាងក្រៃលែងដែលបានផ្តល់នូវរសជាតិភេសជ្ជៈកូកា-កូឡាដ៏ត្រជាក់ ចំពោះអ្នកចូលរួម ដែលញ៉ាំងឱ្យពិធីបុណ្យអុំទូកនាឆ្នាំនេះមានភាពសប្បាយរីករាយយ៉ាងអធិកអធម" នេះជាប្រសាសន៍របស់អ្នកស្រី ជីនីស្ស ឡូវីន ។

ក្រុមហ៊ុនភេសជ្ជៈកម្ពុជា គឺជាក្រុមហ៊ុនជាកម្មសិទ្ធរបស់ក្រុមហ៊ុន កូកា-កូឡា មួយរយភាគរយ ហើយបានផលិតនូវភេសជ្ជៈកូកា-កូឡា ស្រ្តែត៍ ហ្វាន់តា និង F&N ដែលមានរោងចក្រនៅទីក្រុងភ្នំពេញ។ រាល់ដំណើរការផលិតរបស់ក្រុមហ៊ុន គឺអនុវត្តន៍ទៅតាមបទដ្ឋាននៃប្រពន្ធ័គុណភាពកូកា-កូឡាយ៉ាងតឹងរឹងបំផុត ហើយនៅក្នុងឆ្នាំ ១៩៩៩ ក្រុមហ៊ុនភេសជ្ជៈកម្ពុជា (កូកា-កូឡា) បានទទួលមេដាយប្រាក់ស្តីពីគុណភាពល្អឯកលើការងារផលិត និង ផលិតផលរបស់ខ្លួន ពីក្រុមហ៊ុនកូកា-កូឡាប្រចាំអាស៊ីអាគ្នេយ៍ ។

សំរាប់ពត៌មានបន្ថែម សូមបំនាក់ទំនងតាមអាសយដ្ឋានខាងក្រោមនេះ:

ជីនីស្ស ឡូវីន
នាយកក្រុមហ៊ុនភេសជ្ជៈកម្ពុជា (កូកា-កូឡា)
អគារលេខ ២៨៧ ភូមិមិត្តភាព (ផ្លូវជាតិលេខ៥)
ឃុំឫស្សីកែវ ភ្នំពេញ
ទូរស័ព្ទ: ៤២ ៨៩ ៩៥-៦
ទូរសារ: ៤២ ៨៩ ៩២